**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ
# របស់មន្ត្រីអធិការកិច្ចទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែ[illegible] ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩[illegible] [illegible]រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍/.



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០២ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍សម្រាប់ប្រើប្រាស់បំពេញការងារ ចុះអនុវត្តច្បាប់ស្តីពីទេសចរណ៍និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវបានកំណត់ដូចខាងក្រោម៖

**ក- ចំពោះបុរស**

១- **អាវ** មាន៣ (បី)ប្រភេទ៖

- អាវធំវ៉ារីដៃវែងសម្រាប់ពិធីការ
- អាវសាហារីយែនដៃខ្លីសម្រាប់ការងារអធិការកិច្ច
- អាវសាមិដៃវែងសម្រាប់ពាក់ក្នុងអាវធំ

**១.១- អាវធំវ៉ារីដៃវែងសម្រាប់ពិធីការ មាន២ (ពីរ) ថ្នាក់៖**

- **ថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្តាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

អាវធំដៃវែងកាត់រាងវ៉ារី ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់សម្រាប់ពាក់ក្រៅខោ មានកបើកពីរសន្លឹកមានប៉ូលស្មានៅសងខាងភ្ជាប់ដោយឡេវមានពណ៌ដូចពណ៌អាវ។ នៅផ្នែកខាងមុខនៃអាវ មានដាក់ឡេវរូបព្រះសង្ហារពណ៌មាសចំនួន៥(ប្រាំ)គ្រាប់ មានហោប៉ៅចំនួន៤(បួន) ហោប៉ៅពីរខាងលើដេរជាលក្ខណៈប៉ះមានពីរផ្នត់ចំកណ្តាល និងមានគម្របរាងស្លឹកពោធិ៍ [illegible] ខាងក្រោមដេរជាលក្ខណៈបោះ និងមានគម្របរាងចតុកោណកែងទាលចុងសងខាង [illegible] ខ្នងអាវ មានដេរថ្នេរពុះចំកណ្តាលខ្នងកាត់ស្រុងវែងជើងត្រង់ មានផែកខ្នងផ្នែកខាង [illegible]


www.pheakdeylaw.com

ដៃអាវកាត់រាងដៃបំពង់ នៅចុងដៃអាវនីមួយៗទុកប្រវែង៧(ប្រាំពីរ)សង្ទីម៉ែត្រ មានដេរខ្សែវេញពណ៌មាសព័ទ្ធជុំវិញ ហើយមានដាក់ភ្ជាប់ឡេវបញ្ឆោតរូបព្រះសង្ហារពណ៌មាសចំនួន៤(បួន)គ្រាប់នៅចន្លោះខ្សែវេញ និងចុងដៃអាវទាំងពីរ (រូបភាពទី១ ឧបសម្ព័ន្ធទី១)។ ឯកសណ្ឋានប្រភេទនេះត្រូវបានប្រើប្រាស់សម្រាប់ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗដោយភ្ជាប់ជាមួយនូវគ្រឿងឥស្សរិយយស (បើមាន)។

- **ថ្នាក់នាយរងការិយាល័យថ្នាក់កណ្ដាល ប្រធាន អនុប្រធានការិយាល័យនៃមន្ទីរទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច**

អាវធំរ៉ាំរីដៃវែង មានគំរូដូចអាវធំរ៉ាំរីថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្ដាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែរ ប៉ុន្តែខុសត្រង់ឡេវអាវព្រះសង្ហារ និងនៅចុងដៃអាវនីមួយៗមានដាក់ខ្សែវេញព័ណ៌ទឹកប្រាក់ (រូបភាពទី២ ឧបសម្ព័ន្ធទី១)។

**១.២- អាវសាហារីយែនដៃខ្លីសម្រាប់ការងារអធិការកិច្ចមាន២(ពីរ)ថ្នាក់**

- **ថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្ដាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

អាវសាហារីយែនដៃខ្លី ផលិតអំពីសាច់ក្រណាត់ពណ៌សសម្រាប់ពាក់ក្រៅខោ មានកបើកពីរសន្លឹក មានដាក់ឡេវរូបព្រះសង្ហារពណ៌មាសចំនួន៥(ប្រាំ)គ្រាប់ មានប៉ូលស្មានៅសងខាងភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មានហោប៉ៅចំនួន៤(បួន) ហោប៉ៅពីរខាងលើដេរជាលក្ខណៈប៉ះមានពីរផ្នត់ចំកណ្ដាល មានគម្របរាងចតុកោណកែងប៉ិតចុងសងខាង ហោប៉ៅពីរខាងក្រោមដេរដូចហោប៉ៅពីរខាងលើដែរ ប៉ុន្តែខុសត្រង់មានទំហំធំជាង។ នៅផ្នែកខាងខ្នងនៃអាវដេរថ្នេរពុះចំកណ្ដាលខ្នងកាត់ស្រុងវែង ជើងត្រង់មានឆែកខ្នងផ្នែកខាងក្រោម (រូបភាពទី៣ ឧបសម្ព័ន្ធទី១)។

- **ថ្នាក់នាយរងការិយាល័យថ្នាក់កណ្ដាល ប្រធាន អនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច**

អាវសាហារីយែនដៃខ្លី មានគំរូដូចអាវថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្ដាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែរ ប៉ុន្តែខុសត្រង់ ឡេវអាវព្រះសង្ហារពណ៌ទឹកប្រាក់ (រូបភាពទី៤ ឧបសម្ព័ន្ធទី១)។

**១.៣- អាវសាមិដៃវែងសម្រាប់ពាក់ក្នុងអាវធំ**

អាវសាមិដៃវែង ផលិតអំពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃកខុប ឡេវជ័រពណ៌សដេរថ្នេរបង្កប់មានហោប៉ៅមួយដេរជាលក្ខណៈប៉ះគ្មានគម្របកាត់ស្រុងវែងជើងត្រង់(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**២- ខោជើងវែង**

ខោជើងវែង ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់ចង្កេះត ដេរថ្នេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅចំហៀងទាំងសងខាងដេរបញ្ឆិតតាមថ្នេរ ចំហៀង[illegible]និងហោប៉ៅក្រោយពីរដេរថ្នេរបង្កប់ និងមានឡេវមួយបង្កប់ (រូបភាពទី៦ ឧបសម្ព័ន្ធទី១)។

**៣- ក្រវ៉ាត់ក**

ក្រវ៉ាត់កមានមួយប្រភេទធ្វើអំពីក្រណាត់ពណ៌ខៀវចាស់លាត (រូបភាពទី៧ ឧបសម្ព័ន្ធទី១)។


www.pheakdeylaw.com

**៤- ស្បែកជើង**

ស្បែកជើងឃ្លុបប្រភេទស្បែក ពណ៌ខ្មៅ មានចងខ្សែ កខ្លី មានកែង និងមានស្រោមជើងពណ៌ខ្មៅ (រូបភាពទី៨ ឧបសម្ព័ន្ធទី១)។

**៥- ខ្សែក្រវ៉ាត់**

ខ្សែក្រវ៉ាត់ផលិតពីស្បែក ពណ៌ខ្មៅ មានក្បាលពណ៌មាស (រូបភាពទី៩ ឧបសម្ព័ន្ធទី១)។

**៦- មួក**

**៦.១- មួកកាស្កែតសម្រាប់បុរស មាន៥(ប្រាំ)ថ្នាក់**

- **ថ្នាក់អធិការ**

មួកកាស្កែត ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួកមានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកំពស់៧,៨សង្ទីម៉ែត្រ និងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារមានកណ្តាប់វ័ណ្ឌ ធ្វើពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្តាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្តាប់វ័ណ្ឌមានកម្រងខ្សែសយក្រងពណ៌មាសចំនួន៦សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌មាស មានទម្រង់ដូចស្វែងក្របីដល់ជើងមួក (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

- **ថ្នាក់អធិការរងនិងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កែត ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួកមានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកំពស់៧,៨សង្ទីម៉ែត្រ និងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារមានកណ្តាប់វ័ណ្ឌធ្វើពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌប៉ែកខាងមុខ មានក្បាំងពណ៌ខ្មៅ។ នៅលើកណ្តាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្តាប់វ័ណ្ឌ មានកម្រងខ្សែសយក្រងពណ៌មាសចំនួន៦សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌មាស មានទម្រង់ដូចស្វែងក្របី ដោយទុកចន្លោះ៤សង្ទីម៉ែត្រពីជើងមួកទាំងសងខាង (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

- **ថ្នាក់នាយការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កែត ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួកមានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកំពស់៧,៨សង្ទីម៉ែត្រ និងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្តាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្តាប់វ័ណ្ឌ មានកម្រងខ្សែសយក្រងពណ៌មាសចំនួន៣សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស មានទម្រង់ដូចស្វែងក្របីដោយទុកចន្លោះ៤សង្ទីម៉ែត្រ ពីជើងមួកទាំងសងខាង (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។



www.pheakdeylaw.com

- **ថ្នាក់នាយរងការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យ មន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កេត មានទម្រង់ដូចមួករបស់នាយការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្តដែរ ប៉ុន្តែខុសគ្នាត្រង់កម្រងខ្សែសយ ឡេវរូបព្រះសង្ហារ និងប៉ាក់ក្បាច់ភ្ញីទេសមានពណ៌ទឹកប្រាក់ (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

- **ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កេត មានទម្រង់ដូចមួករបស់នាយរងការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្តដែរ ប៉ុន្តែខុសគ្នាត្រង់នៅលើជាយក្បាំងមួក មានតែខ្សែសំប៉ែតទំហំ៥មីលីម៉ែត្រ ពណ៌ទឹកប្រាក់ព័ទ្ធវង់ដល់ជើងមួក (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**ខ- ចំពោះនារី**

**១- អាវ មាន៣(បី)ប្រភេទ៖**

- អាវធំរ៉ាំរឹងដៃវែង (សម្រាប់ពិធីការ) មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង (រូបភាពទី១និងទី២ ឧបសម្ព័ន្ធទី១)។
- អាវសាហារីយែនដៃខ្លី (សម្រាប់ការងាររដ្ឋបាលអធិការកិច្ច) មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង (រូបភាពទី៣និងទី៤ ឧបសម្ព័ន្ធទី១)។
- អាវសាមិដៃវែង (សម្រាប់ពាក់ក្នុងអាវធំ) មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង (រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**២- សំពត់**

សំពត់សំឡុយបត់ ផលិតអំពីសាច់ក្រណាត់ពណ៌ខៀវចាស់ (រូបភាពទី១១ ឧបសម្ព័ន្ធទី១)។

**៣- ក្រវ៉ាត់ក**

ក្រវ៉ាត់កមានមួយប្រភេទពណ៌ខៀវចាស់លាតដូចបុរស (រូបភាពទី៧ ឧបសម្ព័ន្ធទី១)។

**៤- ស្បែកជើង**

ស្បែកជើងឃ្លុបប្រភេទស្បែក ពណ៌ខ្មៅ គ្មានចងខ្សែ កខ្លី ឃ្លុបមុខក្រោយមានកែងទាប (រូបភាពទី១២ ឧបសម្ព័ន្ធទី១)។

**៥- មួកសម្បុកសម្រាប់នារី មាន៥(ប្រាំ)ថ្នាក់**

មួកសម្បុកសម្រាប់នារី មានលក្ខណៈដូចមួកកាស្កេត ទៅតាមកម្រិតថ្នាក់នីមួយៗរបស់បុរសដែរ ប៉ុន្តែខុសត្រង់ ហាមជើងមួក ដេរដោយសាច់ក្រណាត់ជុំវិញបត់ភ្ជើយជើងមួកខាងក្រោយ (រូបភាពទី១៣ ឧបសម្ព័ន្ធទី១)។



www.pheakdeylaw.com

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៣ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទេសចរណ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ស្លាកសញ្ញាសម្គាល់រូបសញ្ញាក្រសួងទេសចរណ៍ ត្រូវប៉ាក់ពីលើសាច់ក្រណាត់រាងមូលដែលមានទំហំអង្កត់ផ្ចិត៧សង្ទីម៉ែត្រ ដោយដេរភ្ជាប់ពីលើដើមដៃអាវខាងស្តាំ (រូបភាពទី១៤ ឧបសម្ព័ន្ធទី២)។

២- ស្លាកសញ្ញាមន្ត្រីនគរបាលយុត្តិធម៌ក្រសួងទេសចរណ៍ មានរូបសញ្ញាក្រសួងទេសចរណ៍ធ្វើអំពីលោហធាតុរាងមូលប៉ោងទំហំអង្កត់ផ្ចិត៥សង្ទីម៉ែត្រ ពណ៌មាសផុសឡើង ភ្ជាប់លើបន្ទះស្បែកពណ៌ខៀវចាស់សម្រាប់ព្យួរនៅហោប៉ៅអាវលើខាងស្តាំ។ នៅផ្នែរង្វង់ខាងលើមានសរសេរអក្សរខ្មែរពណ៌មាស "**អធិការកិច្ចទេសចរណ៍**" នៅផ្នែរង្វង់ខាងក្រោមមានសរសេរអក្សរខ្មែរពណ៌មាស "**នគរបាលយុត្តិធម៌**" នៅចុងអង្កត់ផ្ចិតនៃពាក្យទាំងពីរមានលម្អដោយផ្កាចន្ទន៍។ ស្លាកសញ្ញានេះ ត្រូវបានប្រើប្រាស់សម្រាប់មន្ត្រីអធិការកិច្ចទេសចរណ៍ ដែលបានបំពេញនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ (រូបភាពទី១៥ ឧបសម្ព័ន្ធទី២)។

៣- ស្លាកឈ្មោះនិងអត្តលេខត្រូវកំណត់យកស្លាករាងចតុកោណកែងមានបណ្តោយ៩,៦សង្ទីម៉ែត្រ និងទទឹង២,៥សង្ទីម៉ែត្រ ធ្វើអំពីលោហធាតុបិទជ័ររឹងពីលើផ្ទៃខាងក្នុងមានពណ៌ខៀវចាស់ព័ទ្ធដោយខ្សែបន្ទាត់ស្តើងពណ៌មាស។ ផ្នែកខាងមុខ មួយភាគបួននៃស្លាកមានសរសេរអត្តលេខពណ៌មាស និងបីភាគបួន មានសរសេរឈ្មោះជាអក្សរខ្មែរនិងអក្សរឡាតាំងពណ៌មាសនៅខាងក្រោមសម្រាប់ពាក់ពីលើហោប៉ៅអាវលើខាងស្តាំ(រូបភាពទី១៦ ឧបសម្ព័ន្ធទី២)។

៤- ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់នៅចុងកអាវទាំងសងខាង មានទំហំទទឹង៣សង្ទីម៉ែត្រ និងកម្ពស់៣,៥សង្ទីម៉ែត្រ មានរូបសញ្ញាជើងពានទ្រលិខិតបទដ្ឋានគតិយុត្ត ដោយមានរូបកូនសោនិងញញួរខ្វែងពីលើ។ ស្លាកសញ្ញាពណ៌មាសត្រូវបានប្រើប្រាស់ដោយថ្នាក់អធិការ អធិការរង នាយការិយាល័យ ប្រធាន អនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត និងពណ៌ទឹកប្រាក់ ត្រូវបានប្រើប្រាស់ដោយថ្នាក់នាយរងការិយាល័យ ប្រធាន អនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្តរហូតដល់មន្ត្រីអធិការកិច្ច(រូបភាពទី១៧ ឧបសម្ព័ន្ធទី២)។

៥- ស្លាកបណ្ណំគ្រឿងឥស្សរិយយស ត្រូវរៀបតាមលំដាប់លំដោយ ដែលសាមីខ្លួនម្នាក់ៗបានទទួល បណ្ណំគ្រឿងឥស្សរិយយសត្រូវពាក់ពីលើគម្របហោប៉ាវអាវ[illegible]សង្ទីម៉ែត្រ សម្រាប់ចូលរួមពិធីផ្លូវការ(បើមាន)។/ល



www.pheakdeylaw.com

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៤ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវសងខាង មានចំនួន៥(ប្រាំ)ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ថ្នាក់អធិការ**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសបីខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**ន.ក.ទ.**" ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**២- ថ្នាក់អធិការរងនិងថ្នាក់ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសពីរខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**ន.ក.ទ.**" ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៣- នាយការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសមួយខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**ន.ក.ទ.**" ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៤- នាយរងការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌ទឹកប្រាក់ពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌ទឹកប្រាក់មួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌ទឹកប្រាក់។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌ទឹកប្រាក់មួយខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌ទឹកប្រាក់ ព្រមទាំងមានប៉ាក់អក្សរកាត់ "**ន.ក.ទ.**" ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៥- ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត ទទួលបន្ទុកអធិការកិច្ច**

សក្តិស្មាមានផ្ទៃកម្ចីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌ទឹកប្រាក់ពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌ទឹកប្រាក់មួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមាន



www.pheakdeylaw.com

ប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌ទឹកប្រាក់។ ផ្នែកខាងក្រោមមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌ទឹកប្រាក់ ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ទ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

## ជំពូកទី៥
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៥ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ត្រូវបានប្រើប្រាស់ដោយមន្ត្រីអធិការកិច្ចទេសចរណ៍ដើម្បី៖

១- បំពេញការងារប្រចាំថ្ងៃក្នុងអង្គភាព។

២- បំពេញបេសកកម្មពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍និងច្បាប់នានាពាក់ព័ន្ធក្នុងប្រតិបត្តិការ ស្រាវជ្រាវ តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ ធ្វើអធិការកិច្ច ទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងវិស័យទេសចរណ៍។

៣- ចូលរួមក្នុងពិធីបុណ្យជាតិ ប្រជុំ និង/ឬ សន្និសីទផ្លូវការផ្សេងៗទៀត។

៤- ចូលរួមក្នុងសវនាការនៅតុលាការ។

**មាត្រា៦ .-**

មន្ត្រីអធិការកិច្ចទេសចរណ៍ម្នាក់ៗ ត្រូវទទួលបានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ ចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៧ .-**

ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៨ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ត្រូវបន្តរហូតមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ថ្មីមកជំនួស។/.



www.pheakdeylaw.com

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

**រូបភាពទី១ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ...៤៥៦ អនក្រ.បក...ចុះថ្ងៃទី...១៧.....ខែ...កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវធំរំដៃវែង ថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្តាល និងប្រធាន អនុប្រធាន**

**មន្ទីរទេសចរណ៍រាជធានី ខេត្ត សម្រាប់បុរសនិងនារី**



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ

i

**រូបភាពទី២ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី...២៦.....ខែ..កញ្ញា...ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវធំខាំរីដៃវែង ថ្នាក់នាយកដ្ឋានការិយាល័យថ្នាក់កណ្តាល ប្រធាន អនុប្រធានការិយាល័យ នៃមន្ទីរ**

**ទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច សម្រាប់បុរសនិងនារី**



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ

ព្រះរាជាណាចក្រកម្ពុជា
ទីស្តីការគណៈរដ្ឋមន្ត្រី



www.pheakdeylaw.com

**រូបភាពទី៣ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ៩៦៩ អនក្រ.បក ចុះថ្ងៃទី...២២....ខែ..កញ្ញា....ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវសាហារីយែនដៃខ្លី ថ្នាក់អធិការ អធិការរង នាយការិយាល័យថ្នាក់កណ្ដាល**

**និងប្រធាន អនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សម្រាប់បុរសនិងនារី**



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ

ព្រះរាជាណាចក្រកម្ពុជា
ទីស្ដីការគណៈរដ្ឋមន្ត្រី



www.pheakdeylaw.com

# រូបភាពទី៤ ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី០៦.....ខែ...កញ្ញា...ឆ្នាំ២០១៦

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

## អាវសាហារីយែនដៃខ្លី ថ្នាក់នាយរងការិយាល័យថ្នាក់កណ្តាល ប្រធាន អនុប្រធានការិយាល័យ មន្ទីរ ទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច សម្រាប់បុរសនិងនារី



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ



www.pheakdeylaw.com

**រូបភាពទី៥ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ.............ចុះថ្ងៃទី...........ខែ............ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវដៃវែង ពាក់ក្លូងអាវធំ សម្រាប់បុរសនិងនារី**





www.pheakdeylaw.com

**រូបភាពទី៦ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ...១៦៦ អនក្រ.បក ចុះថ្ងៃទី...១៦...ខែ...កញ្ញា...ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ខោជើងវែងសម្រាប់បុរស**



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ



www.pheakdeylaw.com

## រូបភាពទី៧ ឧបសម្ព័ន្ធទី១
## នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...១៦.....ខែ..កញ្ញា.....ឆ្នាំ២០១៦
## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍
## ក្រវ៉ាត់ក សម្រាប់បុរសនិងនារី





www.pheakdeylaw.com

**រូបភាពទី៨ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ.៩៨.អនក្រ.បក.ចុះថ្ងៃទី.២៦....ខែ.កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ស្បែកជើងនិងស្រោមជើងបុរស**



ស្បែកជើង



ស្រោមជើង



www.pheakdeylaw.com

រូបភាពទី៩ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ...១៩៥...អនក្រ.បក ចុះថ្ងៃទី...០៦...ខែ...កញ្ញា...ឆ្នាំ២០១៦

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ខ្សែក្រវ៉ាត់





www.pheakdeylaw.com

**រូបភាពទី១០ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ៥៥៤អនក្រ.បកចុះថ្ងៃទី...១៦....ខែ...កញ្ញា.....ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**មួកកាស្កែត បុរសមានប្រាំថ្នាក់**



ថ្នាក់អធិការ



ថ្នាក់អធិការរងនិងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយការិយាល័យនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយរងការិយាល័យនិងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់មន្ត្រីអធិការកិច្ចនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត

x

www.pheakdeylaw.com

# រូបភាពទី១១ ឧបសម្ព័ន្ធទី១
## នៃអនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី០៦.....ខែ.កញ្ញា....ឆ្នាំ២០១៦
## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍
## សំពត់សំឡូយបត់នារី



ផ្នែកខាងមុខ



ផ្នែកខាងក្រោយ



www.pheakdeylaw.com

រូបភាពទី១២ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ៩៤៤ អនក្រ.បក ចុះថ្ងៃទី...២៤....ខែ...កញ្ញា....ឆ្នាំ២០១៦

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចនេសចរណ៍

ស្បែកជើងនារី





www.pheakdeylaw.com

**រូបភាពទី១៣ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី...១៦....ខែ...កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**មួកសម្បុកសម្រាប់នារី មានគ្រាំថ្នាក់**



ថ្នាក់អធិការ



ថ្នាក់អធិការរងនិងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយការិយាល័យនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយរងការិយាល័យនិងប្រធានការិយាល័យមន្ទីរទេសចរណ៍
រាជធានី ខេត្ត



ថ្នាក់មន្ត្រីអធិការកិច្ចនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍
រាជធានី ខេត្ត



www.pheakdeylaw.com

**រូបភាពទី១៤ ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៦......ខែ...កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ស្លាកសញ្ញាក្រសួងទេសចរណ៍**



www.pheakdeylaw.com

**រូបភាពទី១៥ ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី...២២....ខែ...កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ស្លាកសញ្ញានគរបាលយុត្តិធម៌**






www.pheakdeylaw.com

**រូបភាពទី១៦ ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...១៦.....ខែ...កញ្ញា....ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ស្លាកសញ្ញាសម្គាល់ឈ្មោះ**






www.pheakdeylaw.com

**រូបភាពទី១៧ ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ...៩៩ អនក្រ.បក ចុះថ្ងៃទី...២១....ខែ....កញ្ញា...ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ស្លាកសញ្ញាសម្គាល់ នៅចុងករអាវទាំងសងខាង**





www.pheakdeylaw.com

## រូបភាពទី១៨ ឧបសម្ព័ន្ធទី៣
## នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...២៦...ខែ....កញ្ញា..ឆ្នាំ២០១៦
## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍
## សញ្ញាសក្តិស្មាមានប្រាំថ្នាក់



ថ្នាក់អធិការ



ថ្នាក់អធិការរងនិងប្រធានមន្ទីរ
ទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយការិយាល័យនិងអនុប្រធាន
មន្ទីរទេសចរណ៍រាជធានី ខេត្ត



ថ្នាក់នាយរងការិយាល័យនិង
ប្រធានការិយាល័យមន្ទីរទេសចរណ៍
រាជធានី ខេត្ត



ថ្នាក់មន្ត្រីអធិការកិច្ចនិង
អនុប្រធានការិយាល័យ
មន្ទីរទេសចរណ៍រាជធានី ខេត្ត



www.pheakdeylaw.com